ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿង ព្រហ្មទណ្ឌ
លេខ:៨៦៧
ចុះថ្ងៃទី ១៩-៩-២០១១
សាលដីកា
លេខ: ១៧ ក្រ.IV ច
ចុះថ្ងៃទី ២៥/៤/២០១២

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ក្រចុះថ្ងៃទី០៨ខែកុម្ភៈឆ្នាំ១៩៩៣ បាន បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ២៥ ខែ ៤ ឆ្នាំ ២០១២ ដោយមានសមាសភាពចូលរួមដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៨៦៧ ចុះថ្ងៃទី ១៩-៩-២០១១ រវាង:

-ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងយ៉ាយ ហៅ យ៉ៃ ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិវៀតណាម មុខរបរបើកហាង ខារ៉ាអូខេ ។ ទីកន្លែងកំណើតនៅ ឃុំជូឌុក ស្រុកកៀនយ៉ាង ខេត្តអាងយ៉ាង ប្រទេស វៀត ណាម ទីលំមុនចាប់ខ្លួនក្រុមទី ១២,ភូមិ ៣,សង្កាត់លេខ ៣, ក្រុង-ខេត្តព្រះ សីហនុ ឪពុកឈ្មោះ [redacted] (ស) ,ម្តាយឈ្មោះ [redacted] (រ) ,ប្រពន្ធឈ្មោះ [redacted] ,មានកូន ០៣នាក់ ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ រយៈពេល ០៤ខែ នឹង០៨ថ្ងៃ ពីបទ: សញ្ចារកម្ម ។ ឃុំខ្លួនតាមដីការ លេខ ៨១១ តព/១១ ចុះថ្ងៃទី ២៦-៤-២០១១ ។ **បច្ចុប្បន្ន** ឃុំខ្លួននៅពន្ធនាគារ ក្រុងព្រះសីហនុ ។

**ជាប់ចោទពីបទ:** សញ្ចារកម្ម និង ដឹកនាំគ្រប់គ្រងគ្រឹះស្ថានសម្រាប់ធ្វើពេស្យាចារ ប្រព្រឹត្តនៅ ភូមិ៣ សង្កាត់លេខ៣ ក្រុង-ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី២៥-០១-២០១១បទល្មើសព្រហ្មទណ្ឌដែល មានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៨៤ និងមាត្រា ២៩១ នៃក្រមព្រហ្មទណ្ឌ

១០៨



Scanned with CamScanner

### អំពីអង្គហេតុ

កាលពីថ្ងៃទី២៥-០១-២០១១មន្ត្រីនគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថខេត្តព្រះសីហនុបាន ចុះទៅបង្ក្រាបផ្ទះរបស់ឈ្មោះ [redacted] យ៉ាំងយ៉ាយ ស្ថិតនៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្ត ព្រះសីហនុ បានរំដោះស្ត្រីរកស៊ីផ្លូវភេទចំនួន ០៣នាក់ ដែលមានឈ្មោះ [redacted] ពិសី,[redacted] ធីខាំបាវ និង ឈ្មោះ [redacted] ធីតាព្រមទាំងបានដកហូតស្រោមអនាម័យនៅក្នុងផ្ទះរបស់ឈ្មោះ [redacted] យ៉ាំងយ៉ាយ បាន មួយចំនួន រីឯឈ្មោះ [redacted] យ៉ាំងយ៉ាយ បានរត់គេចខ្លួនបាត់ ហើយសមត្ថកិច្ចបានកសាងសំណុំរឿង បញ្ជូនមកតុលាការ ។

-បានឃើញសាលក្រមសាលាដំបូង ខេត្ត ព្រះសីហនុ ដែលបានសម្រេចសេចក្តី តាមអំណាច សាលក្រមព្រហ្មទណ្ឌលេខ ៖ ៤០ (ប) ចុះថ្ងៃទី ០៥-៨-២០១១ មានខ្លឹមសារដូចខាងក្រោម ៖

-ផ្តន្ទាទោសលើឈ្មោះ [redacted] យ៉ាំងយៃ៉ មានសាវតាជាតិដូចខាងលើដាក់ពន្ធនាគារកំណត់ ៤ (បួន) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ ៛ (បួនលានរៀល) ដាក់ចូលថវិការដ្ឋ ។

*ពីបទៈសញ្ញារកម្ម និងដឹកនាំគ្រប់គ្រងគ្រឹះស្ថានសម្រាប់ធ្វើពេស្យាចារ ប្រព្រឹត្តនៅភូមិ៣សង្កាត់ លេខ ៣ ក្រុងព្រះសីហនុ ,ខេត្ត ព្រះសីហនុ កាលពីថ្ងៃទី ២៥-០១-២០១១ បទល្មើសព្រហ្មទណ្ឌដែល មានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៨៤ និងមាត្រា ២៩១ នៃក្រមព្រហ្មទណ្ឌ ។*

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៥ខែសីហា ឆ្នាំ២០១១ ទុកសិទ្ធិ ឲ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញសេចក្តីសុំប្តឹងឧទ្ធរណ៍លេខ ៣១ ចុះថ្ងៃទី ២៩-៨-២០១១របស់ឈ្មោះ [redacted] យ៉ាំង យៃ៉ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ៤០"ប" ចុះថ្ងៃទី០៥-៨-២០១១របស់សាលាដំបូង ខេត្តព្រះសីហនុ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

- បានឃើញរបាយការណ៍របស់ចៅក្រមរបាយការណ៍ចុះថ្ងៃទី២៦-០១-២០១២

-បានឃើញរបាយការណ៍សន្និដ្ឋានរបស់តំណាងមហាអយ្យការចុះថ្ងៃទី ២៧-០២-២០១២ ។

### នាពេលសវនាការ

### ចៅក្រមអានរបាយការណ៍សង្ខេបអង្គហេតុ

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងយ៉ាយ បានឆ្លើយថា មុនពេល ស មត្ថកិច្ចចាប់ខ្លួន ។ បានបើកប្រកបមុខរបរ បើកហាង ខារ៉ាអូខេ ដែលមានឈ្មោះ ម្ទប់ដួងចាំស្នេហ៍ នៅ នឹងផ្ទះរបស់ខ្លួនផ្ទាល់តែម្តង ស្ថិតនៅភូមិ៣ សង្កាត់លេខ ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

ផ្ទះរបស់ខ្លួនពុំមានបន្ទប់ទេដោយក្នុងផ្ទះរៀបចំតុ និងសាឡុងសម្រាប់ឲ្យភ្ញៀវអង្គុយ ហើយនៅ ខាងក្រោយផ្ទះមានបន្ទប់មួយសម្រាប់ដាក់គ្រែមួយឲ្យចុងភៅដេកស្នាក់នៅទីនេះ ។ ក្នុងការដែលខ្លួន បើកហាងខារ៉ាអូខេ មានស្រីសម្រាប់រត់តុ លើកស្រាបៀរ និងធ្វើម្ហូបអាហារចំនួន ០៣នាក់ ដែលមាន ឈ្មោះ [redacted] ធីតា,[redacted] ធីខាំបាវ និងឈ្មោះ [redacted] ពិសី ហើយចំពោះស្រីទាំង០៣នាក់នេះវាមិនដេកនៅ ផ្ទះរបស់ខ្លួនទេ គឺវាដេកនៅផ្ទះជួលរបស់ពួកវាផ្សេង ហើយពួកស្រីៗនេះខ្លួនឲ្យប្រាក់ខែ ក្នុង១ខែ៥០$ (ហាសិបដុល្លារអាមេរិក) ខ្លួនបើកហាង ខារ៉ាអូខេ ចាប់ពីម៉ោង ១៨ʰ រហូតដល់ម៉ោង ២៣ʰ ទើបខ្លួន



Scanned with CamScanner

បិទហាង។ កន្លងមកពួកស្រីៗ ទាំងអស់នេះមិនដែលរួមភេទនៅនឹងផ្ទះរបស់ខ្លួនទេ តែត្រូវពួកគេទៅរួមភេទនៅទីណានោះខ្លួនមិនបានដឹងឡើយ។ ចំពោះស្រោមអនាម័យដែលសមត្ថកិច្ចដកហូតនៅផ្ទះរបស់ខ្លួន ខ្លួនមិនដឹងថាជារបស់អ្នកណាទេ។ចំពោះចម្លើយឈ្មោះ [redacted] ពិសី បានថា ជនជាតិបរទេសរួមភេទនៅផ្ទះខ្លួនជាមួយស្រីៗ ក្នុងតម្លៃពី ៣ $ (បីដុល្លារអាមេរិក)ទៅ ៥$ (ប្រាំដុល្លារអាមេរិក)ហើយស្រីដែលរួមភេទថា បានឲ្យលុយមកខ្លួនចំនួន ៥.០០០៛ជាចម្លើយមិនពិតឯងចម្លើយរបស់ឈ្មោះ [redacted] ធីវ៉ាបាវ ក៏ជាចម្លើយមិនពិតដែរ ។ ខ្លួននៅតែអះអាងថា ផ្ទះរបស់ខ្លួនបើកហាង ខារ៉ាអូខេ តែប៉ុណ្ណោះដោយពុំឲ្យស្រីៗ ទាំងនោះរួមភេទជាមួយភ្ញៀវនៅផ្ទះរបស់ខ្លួនឡើយ ។

***សំណូមពរៈ***សុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្លួនផង ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ពិសី ជាស្រីបំរើស្រាបៀរម្នាក់នៅក្នុងចំណោមស្រី ០៤ នាក់ ទៀតក្នុងហាងម្ជប់ដួងចាំស្នេហ៍ ដែលមានម្ចាស់ហាងឈ្មោះ [redacted] យ៉ាំងវ៉ៃ បានឆ្លើយថា ខ្លួនធ្វើការក្នុងហាងនេះបានប្រហែលរយៈពេលជិតមួយឆ្នាំមកហើយ។ខ្លួនដឹងថាក្នុងហាងនេះមានបំរើលក់ស្រាបៀរ បើកខារ៉ាអូខេ និងបំរើសេវាផ្លូវភេទ ។ ក្នុងផ្ទះមានបន្ទប់ពីរ សម្រាប់បំរើសេវាផ្លូវភេទ ដោយស្រីៗ ម្នាក់ត្រូវបង់លុយ ៥.០០០៛ ថ្លៃបន្ទប់ក្នុងការរួមភេទជាមួយភ្ញៀវម្នាក់ទៅម្ចាស់ហាងឈ្មោះ [redacted] យ៉ាំងវ៉ៃ ដោយឡែកចំពោះពេលភ្ញៀវនាំស្រីៗ ក្នុងហាងទៅដេកនៅខាងក្រៅត្រូវបង់ប្រាក់ចំនួន ២០.០០០៛ "ពីម៉ឺនរៀល" ។ តាមធម្មតាហាងនេះមិនសូវជាដាច់ប៉ុន្មានទេ ខ្លួនធ្វើការចាប់ពីម៉ោង០៧ព្រឹក ដល់ម៉ោង១៨ ពាក់កណ្តាលអាធ្រាត្រដោយទទួលបានកំរៃប្រាក់ចំនួន ៥០$ "ហាសិបដុល្លារអាមេរិក" ក្នុង ១ខែ ។ តាមធម្មតាការរួមភេទជាមួយភ្ញៀវពួកខ្លួនមិនបានកំណត់តម្លៃទេ គឺអាស្រ័យតាមភ្ញៀវឲ្យប៉ុណ្ណោះ ,ប៉ុន្តែចាំបាច់ ពួកខ្លួនត្រូវបង់ថ្លៃបន្ទប់ទៅឲ្យឈ្មោះ [redacted] យ៉ាំងវ៉ៃ ចំនួន ៥.០០០៛ ក្នុងភ្ញៀវម្នាក់នៅពេលភ្ញៀវនាំចេញក្រៅត្រូវបង់ប្រាក់ទៅឲ្យឈ្មោះ [redacted] យ៉ាំងវ៉ៃ ចំនួន ២០.០០០៛ខ្លួនសន្យាថា ឈប់ប្រកបការងារនេះតទៅទៀតហើយ ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ធីវ៉ាបាវ បានឆ្លើយថាៈ កន្លងមកខ្លួនធ្លាប់បានឃើញជនជាតិបរទេសដែលសមត្ថកិច្ចឃាត់ខ្លួននេះយកស្រីជនជាតិខ្មែរដែលរស់នៅក្នុងហាងនេះ ទៅរួមសិចនៅខាងក្រៅហាង ជួនពេលខ្លះ រួមសិច នៅក្នុងហាងនេះតែម្តង ។ ប៉ុន្តែខ្លួនពុំដឹងថាគេឲ្យលុយប៉ុន្មានទេ។ ចំណែកខ្លួនពុំបានរួមសិច ជាមួយភ្ញៀវទេ ក្រៅពីនេះខ្លួនពុំបានដឹងឡើយ ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ធីតា បានឆ្លើយថាៈនៅវេលាម៉ោងប្រហែល២៣ ៣០ នាទី នៅថ្ងៃទី ២៥-០១-២០១១ ស្រាប់តែសមត្ថកិច្ចទៅដល់ ខ្លួននិងបុរសម្នាក់ ជនជាតិបរទេសកំពុងតែនៅក្នុងបន្ទប់ផ្ទះរបស់ យាយ ហា នៅភូមិថ្មី ស្ថិតនៅក្រុមទី ១២ ភូមិ៣ សង្កាត់លេខ ៣ ក្រុង-ខេត្តព្រះសីហនុ ស្រាប់តែឈ្មោះ ស៊ុត "អ្នកចាក់ឌីស" ទៅគោះទ្វារហៅខ្លួន និងបុរសនោះឲ្យចេញមកក្រៅ ពេលនោះខ្លួនចេញមកក្រៅមុនបុរសនោះ ស្រាប់តែឃើញសមត្ថកិច្ច , ចំណែកបុរសនោះ ចូលដេកក្រោមគ្រែ ហើយសមត្ថកិច្ចបានហៅបុរសនោះ ចេញពីក្រោមគ្រែ ហើយឆែកទៅលើខ្លួនប្រាណគាត់ សមត្ថកិច្ចក៏យកកាបូបចេញពីខ្លួនយកមកទុកមួយដុំ និងឲ្យអង្គុយចុះ ហើយឆែកទៅលើខ្លួនប្រាណ

គ្រប់គ្នា រួចក៏ឲ្យទៅអង្គុយនៅកន្លែងលក់ស្រាបៀរ នៅស្ងៀម ហើយហៅពួកខ្លួនឡើងជិះរថយន្តមកអង្គភាពកងរាជអាវុធហត្ថដើម្បីសាកសួរ។ នៅក្នុងហាងដើមដូងចាំស្នេហ៍ គឺមានបុគ្គលិកចំនួន ៤នាក់ មានឈ្មោះ ធី,ផុក,ឡុង និងរូបខ្លួនគឺសុទ្ធតែស្រី ហើយជាជនវៀតណាម បច្ចុប្បន្ននៅតែស្រី៣នាក់ ឯឈ្មោះ ឡុង ទៅផ្ទះវិញហើយ និងមានបុរសម្នាក់ចាក់ឪស។ ខ្លួនបំរើការងារនៅក្នុងហាងបានប្រាក់ខែ ៦០០.០០០៛ ក្នុង ១ខែ ជាអ្នកលក់ស្រាបៀរ ដាក់ទឹកកក និងធ្លាប់អង្គុយកំដរភ្ញៀវពេលភ្ញៀវត្រូវការឲ្យទៅក្រៅខ្លួនមិនទៅទេ ប៉ុន្តែពេលចប់ការងារខ្លួនត្រឡប់ទៅផ្ទះវិញ ។

**សេចក្តីសន្និដ្ឋានរបស់មេធាវី**

-តាមចម្លើយជនជាប់ចោទ និងសាក្សី មានលក្ខណៈខុសគ្នានិង · ឈ្មោះ [redacted] ពិសី ។

-កូនក្តីថា មានបន្ទប់តែមួយ រីឯឈ្មោះ [redacted] ពិសី ថាមានបន្ទប់ ពីរ ។

**សំណូមពរៈ** សុំឲ្យក្រុមប្រឹក្សាមេត្តាចាត់របៀប ។

**សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ**

-តាមអំណានចម្លើយជនជាប់ចោទបានបដិសេធ ។

-តាមអំណានចម្លើយសាក្សី ឈ្មោះ [redacted] ធីតា ,ឈ្មោះ [redacted] ពិសី ឃើញថាមានជាតុគ្រប់គ្រាន់ដែលជាកស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ។

-សាលក្រមសាលាដំបូងខេត្ត ព្រះសីហនុ ដែលបានសម្រេចសេចក្តី មានលក្ខណៈត្រឹមត្រូវ ។ គប្បីតម្កល់ សាលក្រមព្រហ្មទណ្ឌលេខ ៤០ (ច) ចុះថ្ងៃទី ០៥-៨-២០១១ របស់សាលាដំបូងខេត្ត ព្រះសីហនុ ទុកជាបានការ ។

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់

**សាលាឧទ្ធរណ៍**

**យល់ឃើញថា**

១/ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៩ សីហា ២០១១ របស់ឈ្មោះ [redacted] យ៉ាំងវៃ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤០ "ច" ចុះថ្ងៃទី ០៥/៨/២០១១ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២/ទោះជាជនត្រូវចោទឈ្មោះ [redacted] យ៉ាំងវៃ បានឆ្លើយបដិសេធថា ខ្លួនគ្រាន់តែបើកហាងខារ៉ាអូខេ ទេហើយពួកស្រីៗ ដែលនៅក្នុងផ្ទះខ្លួននោះពុំដែលរួមភេទនៅនឹងផ្ទះរបស់ខ្លួនទេ។ ក៏ចម្លើយនេះមិនអាចឲ្យតុលាការជឿបានទេ ពីព្រោះចម្លើយរបស់ឈ្មោះ [redacted] ពិសី នឹងឈ្មោះ [redacted] ធីខាំបាវ ដែលជាអ្នកបំរើការងារនៅក្នុងហាងបានបំភ្លឺប្រហែលគ្នាថាផ្ទះនេះបើកខារ៉ាអូខេ និងបំរើសេវ៉ាផ្លូវភេទៗ ក្នុងផ្ទះមានបន្ទប់ពីរសម្រាប់បំរើសេវ៉ាផ្លូវភេទនេះ ដោយស្រីៗ ម្នាក់បង់សុយ ៥.០០០៛ ថ្ងៃ

បន្ទប់ក្នុងការរួមភេទជាមួយភ្ញៀវម្នាក់ទៅម្ចាស់ហាង ។ ចម្លើយ [redacted] ធីនាំបាវ ថាភ្ញៀវជួនកាលរួមសិចក្នុងហាងនេះតែម្ដង ។

៣/សាលក្រមព្រហ្មទណ្ឌលេខ ៤០ -ច - ចុះថ្ងៃទី ០៥/៨/២០១១ របស់សាលាដំបូង ខេត្តព្រះសីហនុ បានសម្រេចត្រឹមត្រូវហើយ ។ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមទុកជាបានការ ។

**<u>ហេតុដូច្នេះ</u>**

**<u>វិនិច្ឆ័យសេចក្ដី</u>**

១/ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៩/៨/២០១១ របស់ឈ្មោះ [redacted] យ៉ាំងវ៉ៃ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះអង្គច្បាប់ ។

២/តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤០ -ច- ចុះថ្ងៃទី ០៥/៨/២០១១ ទុកជាបានការដដែល។

៣/បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥/៤/២០១២ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ កំបាំងមុខជនជាប់ចោទ បើកផ្លូវប្ដឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់ ។

**សេចក្តីនេះព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង អគ្គកម្លាំងប្រដាប់អាវុធជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវ តាមច្បាប់ ។**

| | | |
|---|---|---|
| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| លោក [redacted] | លោក [redacted] | លោក [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ថ្ងៃទី ០១ ខែ ៤ ឆ្នាំ ២០១៤

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner